# សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល
# និង
# ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល

## ជេអេស លែន ភីអិលស៊ី

គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ និងសម្រាប់ត្រីមាស
និងសម្រាប់ជំណាច់ការិយបរិច្ឆេទ ៩ខែដែលបានបញ្ចប់

# មាតិកា


| | ទំព័រ |
|---|---|
| **សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល** | ១ |
| **ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល** | |
| របាយការណ៍ស្តីពីការត្រួតពិនិត្យព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល | ២ - ៣ |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល | ៤ - ៥ |
| របាយការណ៍ចំណូលលម្អិតសង្ខេបចន្លោះពេល | ៦ - ៧ |
| របាយការណ៍បម្រែបម្រួលមូលធនសង្ខេបចន្លោះពេល | ៨ - ៩ |
| របាយការណ៍លំហូរសាច់ប្រាក់សង្ខេបចន្លោះពេល | ១០ - ១១ |
| កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល | ១២ - ៣៨ |

# សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល ភ្ជាប់ជាមួយនឹងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី (ហៅកាត់ថា "ក្រុមហ៊ុន") គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ ដែលមានរបាយការណ៍ចំណូលលម្អិតសង្ខេបចន្លោះពេល របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ត្រីមាស និងសម្រាប់ដំណាច់ការិយបរិច្ឆេទ ៩ខែដែលបានបញ្ចប់រួមទាំងកំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល ត្រូវបានរៀបចំឡើងដោយបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវជាសារវន្តស្របតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជាលេខ ៣៤ ស្តីពី *របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល*។

ចុះហត្ថលេខាជំនួសឱ្យក្រុមប្រឹក្សាភិបាល

ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី JS LAND PLC. KINGDOM OF CAMBODIA

**ឧកញ៉ា កួយ ឡេសាន**
**ប្រធានក្រុមប្រឹក្សាភិបាល**

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២

Grant Thornton

# របាយការណ៍ស្តីពីការត្រួតពិនិត្យព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល

**ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត**
ជាន់ទី២០ អគារកាណាឌីយ៉ា
៣១៥ ផ្លូវព្រះអង្គឌួង
(កែងមហាវិថីព្រះមុនីវង្ស)
សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

លេខទូរស័ព្ទ +៨៥៥ ២៣ ៩៦៦ ៥២០
www.grantthornton.com.kh

**ជូនចំពោះភាគហ៊ុនិករបស់**
**ក្រុមហ៊ុន ដេអេស លែន ភីអិលស៊ី**

យើងខ្ញុំបានធ្វើការត្រួតពិនិត្យទៅលើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ដេអេស លែន ភីអិលស៊ី (ហៅកាត់ថា "ក្រុមហ៊ុន") រួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុចន្លោះពេលគិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ ព្រមទាំងរបាយការណ៍ចំណូលលម្អិតចន្លោះពេល របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ត្រីមាស និងសម្រាប់ដំណាច់ការិយបរិច្ឆេទ ៩ខែ ដែលបានបញ្ចប់ រួមទាំងសេចក្តីពន្យល់លើកំណត់សម្គាល់ ("ព័ត៌មានហិរញ្ញវត្ថុ")។ ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ទទួលខុសត្រូវក្នុងការរៀបចំ និងបង្ហាញជូននូវរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ ដោយអនុលោមតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជាលេខ ៣៤ ស្តីពី *របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល*។ ការទទួលខុសត្រូវរបស់យើងខ្ញុំគឺធ្វើសេចក្តីសន្និដ្ឋានទៅលើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ ដោយផ្អែកទៅលើការត្រួតពិនិត្យរបស់យើងខ្ញុំ។

## វិសាលភាពនៃការត្រួតពិនិត្យ

យើងខ្ញុំបានធ្វើការត្រួតពិនិត្យដោយអនុលោមតាមស្តង់ដារអន្តរជាតិនៃកម្ពុជា លើការត្រួតពិនិត្យលេខ ២៤១០ ស្តីពី *ការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដែលអនុវត្តដោយសវនករឯករាជ្យរបស់ក្រុមហ៊ុន*។ ការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលរួមមាន ការចោទសួរជាចម្បងទៅកាន់បុគ្គលដែលទទួលខុសត្រូវលើបញ្ហាគណនេយ្យ និងហិរញ្ញវត្ថុរួមទាំងការអនុវត្តតាមនីតិវិធីក្នុងការវិភាគ និងនីតិវិធីក្នុងការត្រួតពិនិត្យផ្សេងទៀត។ ការត្រួតពិនិត្យនេះមានវិសាលភាពតិចជាងការធ្វើសវនកម្មដែលធ្វើឡើងដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ដូច្នេះហើយយើងខ្ញុំមិនធានាថា យើងខ្ញុំនឹងដឹងអំពីបញ្ហាសំខាន់ៗ ទាំងអស់ដែលអាចនឹងត្រូវបានកំណត់អត្តសញ្ញាណដូចការធ្វើសវនកម្មនោះទេ។ ហេតុនេះហើយ យើងខ្ញុំមិនបញ្ចេញមតិយោបល់សវនកម្មទេ។

## សេចក្តីសន្និដ្ឋាន

ផ្អែកទៅលើការត្រួតពិនិត្យរបស់យើងខ្ញុំ មិនមានបញ្ហាណាមួយគួរឱ្យកត់សម្គាល់ ដែលជាហេតុធ្វើឱ្យយើងខ្ញុំមានការជឿជាក់ថាព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន មិនបានរៀបចំត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ដោយអនុលោមតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជាលេខ ៣៤ ស្តីពី *របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល* នោះទេ។

Grant Thornton

## បញ្ហាផ្សេងទៀត

ព័ត៌មានប្រៀបធៀបក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ គឺអាស្រ័យទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលបានធ្វើសវនកម្មរួចគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។ ព័ត៌មានប្រៀបធៀបសម្រាប់ត្រីមាស និងសម្រាប់ដំណាច់ការិយបរិច្ឆេទ ៩ខែដែលបានបញ្ចប់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ក្នុងរបាយការណ៍ចំណូលលម្អិត របាយការណ៍លំហូរសាច់ប្រាក់ រួមទាំងសេចក្ដីពន្យល់ក្នុងកំណត់សម្គាល់ ត្រូវបានត្រួតពិនិត្យ ប៉ុន្តែមិនបានធ្វើសវនកម្មនោះទេ។

ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត
គណនេយ្យករជំនាញ
សវនករប្រតិស្រុតចុះបញ្ជី

Ng Yee Zant
នាយកសវនករជំនាញ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល

| | | (បានត្រួតពិនិត្យ តែមិនបាន ធ្វើសវនកម្ម) | | (បានធ្វើសវនកម្មរួច) | |
|---|---|---|---|---|---|
| | | **ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២** | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
| | កំណត់សម្គាល់ | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់ ៣)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) |
| **ទ្រព្យសកម្ម** | | | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | | | |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ៦ | **៦៥៨.៥១៨** | **២.៧១២.៤៣៦** | ៦៦៥.៤៦១ | ២.៧១១.០៨៨ |
| សិទ្ធិប្រើប្រាស់លើទ្រព្យសកម្ម | ១៣ | **៤៦.៣០០** | **១៩០.៧១០** | ៩៣.៩៩១ | ៣៨២.៩១៩ |
| **ទ្រព្យសកម្មរយៈពេលវែងសរុប** | | **៧០៤.៨១៨** | **២.៩០៣.១៤៦** | ៧៥៩.៤៥២ | ៣.០៩៤.០០៧ |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | | | |
| សន្និធិអចលនទ្រព្យ | ៧ | **៧៦.២៤៦** | **៣១៤.០៥៧** | ៧៦.២៤៦ | ៣១០.៦២៦ |
| ថ្លៃដើមអភិវឌ្ឍទ្រព្យសម្បត្តិ | ៨ | **៩.២៩៣.៣៨២** | **៣៨.២៧៩.៤៤០** | ៥.៤៤៨.០៧៥ | ២២.១៩៥.៤៥៨ |
| ថ្លៃដើមកិច្ចសន្យា | ៩ | **១៣៥.៨៤៣** | **៥៥៩.៥៣៧** | ១០៥.៤៣៦ | ៤២៩.៥៤៦ |
| ទ្រព្យសកម្មកិច្ចសន្យា | ១០ | **២.៧៦៧.៤៥៤** | **១១.៣៩៩.១៤៣** | ២.៩៩៣.០៦៦ | ១២.១៩៣.៧៥១ |
| គណនីត្រូវទទួល | ១០ | **៦៥.៨៥០** | **២៧១.២៣៦** | ១៩.៣៩០ | ៧៨.៩៩៥ |
| ចំណាយបង់មុន និងគណនីត្រូវទទួលផ្សេងៗ | ១១ | **៣៣៧.៣០៦** | **១.៣៨៩.៣៦៣** | ៥៦៤.៥៩៤ | ២.៣០០.១៥៦ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ១២ | **២២១.៤៣៨** | **៩១២.១០៣** | ២០៧.៦០១ | ៨៤៥.៧៦៦ |
| **ទ្រព្យសកម្មរយៈពេលខ្លីសរុប** | | **១២.៨៩៧.៥១៩** | **៥៣.១២៤.៨៧៩** | ៩.៤១៤.៤០៨ | ៣៨.៣៥៤.២៩៨ |
| **ទ្រព្យសកម្មសរុប** | | **១៣.៦០២.៣៣៧** | **៥៦.០២៨.០២៥** | ១០.១៧៣.៨៦០ | ៤១.៤៤៨.៣០៥ |
| **មូលធន និងបំណុល** | | | | | |
| **មូលធន** | | | | | |
| ដើមទុន | ១៤ | **៦៤២.៧៥០** | **២.៥៧១.០០០** | ៥០០.០០០ | ២.០០០.០០០ |
| បុព្វលាភភាគហ៊ុន | ១៥ | **២.៤០០.៤៥៨** | **៩.៦០១.៨៣២** | - | - |
| (ខាតបង្គរ)/ប្រាក់ចំណេញរក្សាទុក | | **(៨៧៩.៣៤៥)** | **(៣.៥៧៩.០៣៧)** | ២៣២.២៣០ | ៩៤៩.៥២០ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | **៣១៩.១៥៧** | - | ៣៣.៥៨៥ |
| **មូលធនសរុប** | | **២.១៦៣.៨៦៣** | **៨.៩១២.៩៥២** | ៧៣២.២៣០ | ២.៩៨៣.១០៥ |

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)

| | កំណត់សម្គាល់ | (បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម) ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ ដុល្លារអាមេរិក | ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ ពាន់រៀល (កំណត់សម្គាល់ ៣) | (បានធ្វើសវនកម្មរួច) ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ដុល្លារអាមេរិក | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ពាន់រៀល (កំណត់សម្គាល់ ៣) |
|---|---|---|---|---|---|
| **បំណុល** | | | | | |
| **បំណុលរយៈពេលវែង** | | | | | |
| ប្រាក់កម្ចី | ១៧ | **៣.៣៥១.៦២១** | **១៣.៨០៥.៣២៧** | ១.៩៧៥.៩៨៩ | ៨.០៥០.១៧៨ |
| បំណុលភតិសន្យា | ១៣ | **-** | **-** | ៣២.៦១៩ | ១៣២.៨៩០ |
| **បំណុលរយៈពេលវែងសរុប** | | **៣.៣៥១.៦២១** | **១៣.៨០៥.៣២៧** | **២.០០៨.៦០៨** | **៨.១៨៣.០៦៨** |
| **បំណុលរយៈពេលខ្លី** | | | | | |
| បំណុលកិច្ចសន្យា | ១០ | **៣.០៣២.៨៨៦** | **១២.៤៩២.៤៥៧** | ១.៥៩៨.៩៣១ | ៦.៥១៤.០៤៥ |
| គណនីពាណិជ្ជ និងគណនីត្រូវសងផ្សេងៗ | ១៦ | **១.៩៩៧.១៩៩** | **៨.២២៦.៤៦១** | ២.៦៣៨.០៣៦ | ១០.៧៤៧.៣៥៧ |
| ប្រាក់កម្ចី | ១៧ | **១.៩០៣.០៧៨** | **៧.៨៣៨.៧៧៨** | ១.៧៩៣.០៩០ | ៧.៣០៥.០៥០ |
| បំណុលភតិសន្យា | ១៣ | **៤៨.៤៧៧** | **១៩៩.៦៧៧** | ៦៤.៤៣១ | ២៦២.៤៩២ |
| សមតុល្យជំពាក់ម្ចាស់ភាគហ៊ុន | ១៩ | **១.០៩៧.៥៩៧** | **៤.៥២១.០០២** | ១.២៦៨.៤៥៩ | ៥.១៦៧.៧០២ |
| ពន្ធលើប្រាក់ចំណូលត្រូវបង់ | ២២(ខ) | **៧.៦១៦** | **៣១.៣៧១** | ៧០.០៧៥ | ២៨៥.៤៨៦ |
| **បំណុលរយៈពេលខ្លីសរុប** | | **៨.០៨៦.៨៥៣** | **៣៣.៣០៩.៧៤៦** | **៧.៤៣៣.០២២** | **៣០.២៨២.១៣២** |
| **បំណុលសរុប** | | **១១.៤៣៨.៤៧៤** | **៤៧.១១៥.០៧៣** | **៩.៤៤១.៦៣០** | **៣៨.៤៦៥.២០០** |
| **មូលធន និងបំណុលសរុប** | | **១៣.៦០២.៣៣៧** | **៥៦.០២៨.០២៥** | **១០.១៧៣.៨៦០** | **៤១.៤៤៨.៣០៥** |

# របាយការណ៍ចំណូលលម្អិតសង្ខេបចន្លោះពេល

| | កំណត់សម្គាល់ | (បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម) សម្រាប់ដំណាច់ការិយបរិច្ឆេទ៩ខែដែលបានបញ្ចប់ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) | (បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម) សម្រាប់ដំណាច់ការិយបរិច្ឆេទ៩ខែដែលបានបញ្ចប់ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) |
|---|---|---|---|---|---|
| ការលក់អចលទ្រព្យ | ១០ | - | - | ១.០៤៨.៤៧៦ | ៤.២៦៣.១០៣ |
| ថ្លៃដើមក្នុងការលក់អចលទ្រព្យ | ៧ | - | - | (៦៥០.១៦៨) | (២.៦៤៣.៥៨៣) |
| **ចំណូលដុល** | | - | - | ៣៩៨.៣០៨ | ១.៦១៩.៥២០ |
| ចំណូលផ្សេងៗ | ២០ | **៣៧.០១២** | **១៥០.៧៨៧** | ១២១.៤៧៧ | ៤៩៣.៩២៥ |
| ចំណាយទូទៅ និងចំណាយរដ្ឋបាល | ២១ | (**១.១៥១.៧២៨**) | (**៤.៦៩២.១៤០**) | (៥០៤.៣៧១) | (២.០៥០.៧៧២) |
| **(ខាត)/ចំណូលប្រតិបត្តិការ** | | (**១.១១៤.៧១៦**) | (**៤.៥៤១.៣៥៣**) | ១៥.៤១៤ | ៦២.៦៧៣ |
| ចំណាយហិរញ្ញវត្ថុ | ១៣ | (**៤.១៧១**) | (**១៦.៩៩៣**) | (៥.០៦១) | (២០.៥៧៨) |
| ចំណូលហិរញ្ញវត្ថុ | ១២,១៩ | **២៤.០០៥** | **៩៧.៧៩៦** | ៥៥២ | ២.២៤៤ |
| **ខាតមុនបង់ពន្ធលើប្រាក់ចំណូល** | | (**១.០៩៤.៨៨២**) | (**៤.៤៦០.៥៥០**) | ១០.៩០៥ | ៤៤.៣៣៩ |
| ចំណាយពន្ធលើប្រាក់ចំណូល | ២២(ក) | (**១៦.៦៩៣**) | (**៦៨.០០៧**) | (១៥.៦២០) | (៦៣.៥១១) |
| **ខាតក្នុងការិយបរិច្ឆេទ** | | (**១.១១១.៥៧៥**) | (**៤.៥២៨.៥៥៧**) | (៤.៧១៥) | (១៩.១៧២) |
| ចំណូលលម្អិតផ្សេងៗ – លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | **២៨៥.៥៧២** | - | ២៣.៩៩២ |
| **(ខាត)/ចំណេញលម្អិតផ្សេងៗសរុបក្នុងការិយបរិច្ឆេទ** | | (**១.១១១.៥៧៥**) | (**៤.២៤២.៩៨៥**) | (៤.៧១៥) | ៤.៨២០ |

ខាតក្នុងមួយសន្លឹកហ៊ុន ដែលបែងចែកទៅឱ្យម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុនក្នុងអំឡុងការិយបរិច្ឆេទមានដូចខាងក្រោម៖

| | | | | | |
|---|---|---|---|---|---|
| ខាតមូលដ្ឋានក្នុងមួយភាគហ៊ុន (សេន/រៀល) | ២៥ | (**០,០៥**) | (**១៨៥,៥៣**) | (**០,០០០៥**) | (១,៨៩) |
| ខាតថយចុះក្នុងមួយភាគហ៊ុន (សេន/រៀល) | ២៥ | (**០,០៥**) | (**១៨៥,៥៣**) | (**០,០០០៥**) | (១,៨៩) |

# របាយការណ៍ចំណូលលម្អិតសង្ខេបចន្លោះពេល (ត)

| | កំណត់សម្គាល់ | (បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម) សម្រាប់ត្រីមាសដែលបានបញ្ចប់ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) | (បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម) សម្រាប់ត្រីមាសដែលបានបញ្ចប់ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) |
|---|---|---|---|---|---|
| ការលក់អចលទ្រព្យ | ១០ | - | - | ៣៨៦.៧៣៨ | ១.៥៧៦.៣៨៤ |
| ថ្លៃដើមក្នុងការលក់អចលទ្រព្យ | ៧ | - | - | (២៣៥.៦៣៣) | (៩៦០.៤៤០) |
| **ចំណូលដុល** | | - | - | ១៥១.១០៥ | ៦១៥.៩០៤ |
| ចំណូលផ្សេងៗ | ២០ | **៤.៩៧៣** | **២០.៣៩៤** | ២០.៤៨៩ | ៨៣.៥១៣ |
| ចំណាយទូទៅ និងចំណាយរដ្ឋបាល | ២១ | (៤៨៥.០៩៤) | (១.៩៨៩.៣៧០) | (១៩៧.៧០១) | (៨០៥.៨២៩) |
| **ខាតប្រតិបត្តិការ** | | (៤៨០.១២១) | (១.៩៦៨.៩៧៦) | (២៦.១០៧) | (១០៦.៤១២) |
| ចំណាយហិរញ្ញវត្ថុ | | (១.១០៤) | (៤.៥២៨) | (១.៥៩១) | (៦.៤៨៥) |
| ចំណូលហិរញ្ញវត្ថុ | | **៩៥៣** | **៣.៩០៨** | ៤៤២ | ១.៨០២ |
| **(ខាត)/ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល** | | (៤៨០.២៧២) | (១.៩៦៩.៥៩៦) | (២៧.២៥៦) | (១១១.០៩៥) |
| ចំណាយពន្ធលើប្រាក់ចំណូល | ២២(ក) | (៧.៦១៦) | (៣១.២៣៣) | ២.៤១៣ | ៩.៨៣៥ |
| **(ខាត)/ចំណេញក្នុងការិយបរិច្ឆេទ** | | (៤៨៧.៨៨៨) | (២.០០០.៨២៩) | (២៤.៨៤៣) | (១០១.២៦០) |
| ចំណូលលម្អិតផ្សេងៗ – | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | **១២១.១៥៥** | - | (១៣៥.៨៩១) |
| **(ខាត)/ចំណេញលម្អិតផ្សេងៗសរុប ក្នុងការិយបរិច្ឆេទ** | | (៤៨៧.៨៨៨) | (១.៨៧៩.៦៧៤) | (២៤.៨៤៣) | (២៣៧.១៥១) |

ខាតក្នុងមួយសន្លឹកហ៊ុន ដែលបែងចែកទៅឱ្យម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុនក្នុងអំឡុងការិយបរិច្ឆេទមានដូចខាងក្រោម៖

| | | | | | |
|---|---|---|---|---|---|
| ខាតមូលដ្ឋានក្នុងមួយភាគហ៊ុន (សេន/រៀល) | ២៥ | (០,០២) | (៧៧,៨២) | (០,០០១២) | (៥,០៦) |
| ខាតថយចុះក្នុងមួយភាគហ៊ុន (សេន/រៀល) | ២៥ | (០,០២) | (៧៧,៨២) | (០,០០១២) | (៥,០៦) |

# របាយការណ៍បម្រែបម្រួលមូលធនសង្ខេបចន្លោះពេល

| | ដើមទុន | | បុព្វលាភភាគហ៊ុន | | ប្រាក់តម្កល់សម្រាប់ទិញ ភាគហ៊ុន នាពេលអនាគត | | (ខាតបង្គរ)/ ប្រាក់ចំណេញរក្សាទុក | | លម្អៀងពីការប្តូររូបិយប័ណ្ណបង្គរ | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) (បានធ្វើចំណាត់ថ្នាក់ឡើងវិញ) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) | ពាន់រៀល (កំណត់សម្គាល់ ៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) |
| (បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម) | | | | | | | | | | | |
| **សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២២** | ៥០០.០០០ | ២.០០០.០០០ | - | - | - | - | ២៣២.២៣០ | ៩៤៩.៥២០ | ៣៣.៥៨៥ | ៧៣២.២៣០ | ២.៩៨៣.១០៥ |
| ភាគហ៊ុនដែលបានបោះផ្សាយ (សម្គាល់ ១៤) | ១៤២.៧៥០ | ៥៧១.០០០ | ២.៤០០.៤៥៨ | ៩.៦០១.៨៣២ | - | - | - | - | - | ២.៥៤៣.២០៨ | ១០.១៧២.៨៣២ |
| ខាតក្នុងការិយបរិច្ឆេទ | - | - | - | - | - | - | (១.១១១.៥៧៥) | (៤.៥២៨.៥៥៧) | - | (១.១១១.៥៧៥) | (៤.៥២៨.៥៥៧) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | ២៨៥.៥៧២ | - | ២៨៥.៥៧២ |
| **សមតុល្យគិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២** | ៦៤២.៧៥០ | ២.៥៧១.០០០ | ២.៤០០.៤៥៨ | ៩.៦០១.៨៣២ | - | - | (៨៧៩.៣៤៥) | (៣.៥៧៩.០៣៧) | ៣១៩.១៥៧ | ២.១៦៣.៨៦៣ | ៨.៩១២.៩៥២ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

# របាយការណ៍បម្រែបម្រួលមូលធនសង្ខេបចន្លោះពេល (ត)

| | ដើមទុន | | បុព្វលាភភាគហ៊ុន | | ប្រាក់តម្កល់សម្រាប់ទិញភាគហ៊ុននាពេលអនាគត | | (ខាតបង្គរ)/ចំណេញរក្សាទុក | | លម្អៀងពីការប្តូររូបិយប័ណ្ណបង្គរ | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) (បានធ្វើចំណាត់ថ្នាក់ឡើងវិញ) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) | ពាន់រៀល (កំណត់សម្គាល់ ៣) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) |
| (បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម) | | | | | | | | | | | |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២១ | ៥.០០០ | ២០.០០០ | - | - | ៣៩៩.០០០ | ១.៥៩៦.០០០ | ៣០៣.៤១៤ | ១.២៣២.៥៦៨ | ១២.៩២២ | ៧០៧.៤១៤ | ២.៨៦១.៤៩០ |
| ខាតក្នុងការិយបរិច្ឆេទ | - | - | - | - | - | - | (៤.៧១៥) | (១៩.១៧២) | - | (៤.៧១៥) | (១៩.១៧២) |
| ការបំលែងប្រាក់តម្កល់សម្រាប់ការជាវភាគហ៊ុននាពេលអនាគតទៅបន្ថែមក្នុងដើមទុន (សម្គាល់ ១៤) | ៣៩៩.០០០ | ១.៥៩៦.០០០ | - | - | (៣៩៩.០០០) | (១.៥៩៦.០០០) | - | - | - | - | - |
| ការបំលែងចំណេញរក្សាទុកទៅបន្ថែមក្នុងដើមទុន (សម្គាល់ ១៤) | ៩៦.០០០ | ៣៨៤.០០០ | - | - | - | - | (៩៦.០០០) | (៣៨៤.០០០) | - | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | ២៣.៩៩២ | - | ២៣.៩៩២ |
| សមតុល្យគិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ | ៥០០.០០០ | ២.០០០.០០០ | - - | | - | - | ២០២.៦៩៩ | ៨២៩.៣៩៦ | ៣៦.៩១៤ | ៧០២.៦៩៩ | ២.៨៦៦.៣១០ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

# របាយការណ៍លំហូរសាច់ប្រាក់សង្ខេបចន្លោះពេល

| | កំណត់សម្គាល់ | **(បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម) សម្រាប់ដំណាច់ការិយបរិច្ឆេទ៩ខែ ដែលបានបញ្ចប់ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់ ៣)** | (បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម) សម្រាប់ដំណាច់ការិយបរិច្ឆេទ៩ខែ ដែលបានបញ្ចប់ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) |
|---|---|---|---|---|---|
| **លំហូរសាច់ប្រាក់បានមកពីសកម្មភាពប្រតិបត្តិការ** | | | | | |
| (ខាត)/ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល | | **(១.០៩៤.៨៨២)** | **(៤.៤៦០.៥៥០)** | ១០.៩០៥ | ៤៤.៣៣៩ |
| **និយ័តកម្មសម្រាប់៖** | | | | | |
| រំលស់ | ២១ | **៥៨.៣៧៥** | **២៣៧.៨២០** | ៦៥.៣៩១ | ២៦៥.៨៨០ |
| ចំណេញពីការបញ្ចប់ភតិសន្យា | ១៣ | **(១.៣៥០)** | **(៥.៥០០)** | (២០.៩១១) | (៨៥.០២៤) |
| ចំណាយហិរញ្ញវត្ថុ | ១៨ | **៣២៣.៧៨៥** | **១.៣១៩.១០០** | ១៦៣.២៣៧ | ៦៦៣.៧២២ |
| ចំណូលហិរញ្ញវត្ថុ | ១២,១៩ | **(២៤.០០៥)** | **(៩៧.៧៩៦)** | (៥៥២) | (២.២៤៤) |
| **(ខាត)/ចំណេញប្រតិបត្តិការមុនបម្រែបម្រួលទុនបង្វិល** | | **(៧៣៨.០៧៧)** | **(៣.០០៦.៩២៦)** | ២១៨.០៧០ | ៨៨៦.៦៧៣ |
| **បម្រែបម្រួលទុនបង្វិលសុទ្ធ** | | | | | |
| បម្រែបម្រួលក្នុង៖ | | | | | |
| ថ្លៃដើមអភិវឌ្ឍទ្រព្យសម្បត្តិ | | **(៣.៨៤៥.៣០៧)** | **(១៥.៦៦៥.៧៨១)** | (២.១៤៣.៥០៣) | (៨.៧១៥.៤៨៣) |
| គណនីត្រូវទទួល | | **(៤៦.៤៦០)** | **(១៨៩.២៧៨)** | ១៩៤.១៧០ | ៧៨៩.៤៩៥ |
| ទ្រព្យសកម្មកិច្ចសន្យា | | **២២៥.៦១២** | **៩១៩.១៤៣** | (៦៧១.៣២៨) | (២.៧២៩.៦២០) |
| ចំណាយបង់មុន និងគណនីត្រូវទទួលផ្សេងៗ | | **២២៧.២៨៨** | **៩២៥.៩៧១** | (១៤៨.៩៨៥) | (៦០៥.៧៧៣) |
| ថ្លៃដើមកិច្ចសន្យា | | **(៣០.៤០៧)** | **(១២៣.៨៧៨)** | (៦១.៤៨៥) | (២៤៩.៩៩៨) |
| សន្និធិអចលនទ្រព្យ | | **-** | **-** | ៦២១.៣៩៧ | ២.៥២៦.៦០០ |
| គណនីពាណិជ្ជ និងគណនីត្រូវសងផ្សេងៗ | | **(៦៤០.៨៣៧)** | **(២.៦១០.៧៧០)** | ២៤២.៧២៧ | ៩៨៦.៩២៨ |
| បំណុលកិច្ចសន្យា | | **១.៤៣៣.៩៥៥** | **៥.៨៤១.៩៣៣** | ៧៧៥.២៦៣ | ៣.១៥២.២១៩ |
| សមតុល្យជំពាក់ម្ចាស់ភាគហ៊ុន | | **(១៧០.៨៦២)** | **(៦៩៦.០៩២)** | (២៤៥.១៦៥) | (៩៩៦.៨៤១) |
| **សាច់ប្រាក់បានប្រើក្នុងប្រតិបត្តិការ** | | (៣.៥៨៥.០៩៥) | **(១៤.៦០៥.៦៧៨)** | (១.២១៨.៨៣៩) | (៤.៩៥៥.៨០០) |
| ពន្ធលើប្រាក់ចំណូលដែលបានទូទាត់ | ២២(ខ) | **(៧៩.១៥២)** | **(៣២២.៤៦៥)** | (១០៣.៩៩៤) | (៤២២.៨៤០) |
| ការប្រាក់ដែលបានទទួល | ១២,១៩ | **២៤.០០៥** | **៩៧.៧៩៦** | ៥៥២ | ២.២៤៤ |
| **សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពប្រតិបត្តិការ** | | **(៣.៦៤០.២៤២)** | **(១៤.៨៣០.៣៤៧)** | (១.៣២២.២៨១) | (៥.៣៧៦.៣៩៦) |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

# របាយការណ៍លំហូរសាច់ប្រាក់ចន្លោះពេល (ត)

| | កំណត់សម្គាល់ | (បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម) សម្រាប់ដំណាច់ការិយបរិច្ឆេទ៩ខែ ដែលបានបញ្ចប់ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ ដុល្លារអាមេរិក | (បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម) សម្រាប់ដំណាច់ការិយបរិច្ឆេទ៩ខែ ដែលបានបញ្ចប់ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ ពាន់រៀល (កំណត់សម្គាល់ ៣) | (បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម) សម្រាប់ដំណាច់ការិយបរិច្ឆេទ៩ខែ ដែលបានបញ្ចប់ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ដុល្លារអាមេរិក | (បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម) សម្រាប់ដំណាច់ការិយបរិច្ឆេទ៩ខែ ដែលបានបញ្ចប់ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ពាន់រៀល (កំណត់សម្គាល់ ៣) |
|---|---|---|---|---|---|
| **សកម្មភាពវិនិយោគ** | | | | | |
| ទិញទ្រព្យសម្បត្តិ និងបរិក្ខារ | ៦ | (៥.១៣១) | (២០.៩០៤) | (៣១.១៣១) | (១២៦.៥៧៩) |
| **សកម្មភាពហិរញ្ញវត្ថុ** | | | | | |
| សាច់ប្រាក់បានពីដើមទុនដែលបានអនុម័ត | | ២.៥៤៣.២០៨ | ១០.៣៦១.០២៩ | - | - |
| ការប្រាក់ដែលបានទូទាត់លើប្រាក់កម្ចី | ១៨ | (១៩៤.៣៧៨) | (៧៩១.៨៩៦) | (៦៩.៤៦២) | (២៨២.៤៣២) |
| ការទូទាត់សងប្រាក់កម្ចី | ១៨ | (៤៨០.៣៦០) | (១.៩៥៦.៩៨៧) | (៩៧៤.០៨៦) | (៣.៩៦០.៦៣៤) |
| ការទូទាត់ចំណែកប្រាក់ដើមនៃបំណុលភតិសន្យា | ១៨ | (៤៥.៨៣៣) | (១៨៦.៧២៤) | (៥២.២០៩) | (២១២.២៨២) |
| ការប្រាក់ដែលបានទូទាត់លើបំណុលភតិសន្យា | ១៨ | (៤.១៧១) | (១៦.៩៩៣) | (៥.០៦១) | (២០.៥៧៨) |
| ការទទួលប្រាក់កម្ចី | ១៨ | ១.៨៤០.៧៤៤ | ៧.៤៩៩.១៩១ | ២.៦០៩.៨៩៣ | ១០.៦១១.៨២៥ |
| **សាច់ប្រាក់សុទ្ធបានមកពីសកម្មភាពហិរញ្ញវត្ថុ** | | ៣.៦៥៩.២១០ | ១៤.៩០៧.៦២០ | ១.៥០៩.០៧៥ | ៦.១៣៥.៨៩៩ |
| **ការថយចុះសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ** | | ១៣.៨៣៧ | ៥៦.៣៦៩ | ១៥៥.៦៦៣ | ៦៣២.៩២៤ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល ដើមគ្រា | | ២០៧.៦០១ | ៨៤៥.៧៦៦ | ២២៦.៤៧០ | ៩១៦.០៧១ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | ៩.៩៦៨ | - | ៩.៧២៦ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលចុងគ្រា** | ១២ | ២២១.៤៣៨ | ៩១២.១០៣ | ៣៨២.១៣៣ | ១.៥៥៨.៧២១ |

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ

## ១. អំពីក្រុមហ៊ុន

ដេអេស លែន ភីអិលស៊ី ដែលពីមុនត្រូវបានគេស្គាល់ជា ដេអេស លែន លីមីធីត ជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតដែលត្រូវបានបង្កើតឡើងក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៤ ដែលអនុលោមតាមអនុស្សរណៈ និងលក្ខន្តិកៈក្រុមហ៊ុន ("MAA") និងមានវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មលេខ ៣២៧៨KH/២០១៤ ចេញដោយក្រសួងពាណិជ្ជកម្ម ("MOC")។ នៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៦ ក្រុមហ៊ុនបានធ្វើការចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មម្តងទៀតដោយទទួលបានលេខចុះបញ្ជីថ្មីលេខ ០០០១០៣៣២។

នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១ ក្រុមហ៊ុនបានធ្វើវិសោធនកម្មទៅលើអនុស្សរណៈ និងលក្ខន្តិកៈក្រុមហ៊ុនរបស់ខ្លួន ដើម្បីអនុវត្តទៅតាមឈ្មោះថ្មីរបស់ក្រុមហ៊ុន ព្រមជាមួយនឹងអាសយដ្ឋានចុះបញ្ជីថ្មីរបស់ខ្លួនដែលមានទីតាំងស្ថិតនៅអគារលេខ B២-១០៧ គម្រោងកោះពេជ្រ Elysee វិថីកោះពេជ្រ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ក្រុមហ៊ុនបានចូលរួមជាចម្បងនូវរាល់សកម្មភាពរបស់ក្រុមហ៊ុនអចលទ្រព្យ ជាពិសេសការអភិវឌ្ឍន៍លើគម្រោងអគារសម្រាប់ប្រតិបត្តិការអាជីវកម្មរបស់ខ្លួនដូចជា ការលក់បន្ទប់នៅក្នុងអគារទាំងនេះ។ បច្ចុប្បន្នក្រុមហ៊ុនកំពុងសាងសង់គម្រោងទីពីររបស់ខ្លួននៅក្នុងខណ្ឌសែនសុខ ដែលត្រូវបានដាក់ឱ្យដំណើរការនៅក្នុងខែវិច្ឆិកា ឆ្នាំ២០២០ ហើយគម្រោងនេះនឹងត្រូវបញ្ចប់នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២៣។ គម្រោងដំបូងត្រូវបានបញ្ចប់នៅក្នុងឆ្នាំ២០១៩។

នៅថ្ងៃទី៤ ខែមីនា ឆ្នាំ២០២២ ក្រុមហ៊ុនបានទទួលជោគជ័យក្នុងការចុះបញ្ជីនៅលើទីផ្សារកំណើននៃផ្សារមូលបត្រកម្ពុជា។ ភាគហ៊ុនថ្មីត្រូវបានបោះផ្សាយចំនួន ៥.៧១០.០០០ ភាគហ៊ុនក្នុងតម្លៃចារឹក ១០០រៀល ឬ០,០២៥ដុល្លារអាមេរិកក្នុងមួយភាគហ៊ុន ក្នុងតម្លៃបោះផ្សាយ ១.៩០០រៀល ឬ០,៤៦ ដុល្លារអាមេរិកក្នុងមួយភាគហ៊ុន។ នាកាលបរិច្ឆេទនៃរបាយការណ៍ អនុស្សរណៈ និងលក្ខន្តិកៈក្រុមហ៊ុន គឺកំពុងស្ថិតនៅក្នុងដំណើរការធ្វើបច្ចុប្បន្នភាពជាមួយក្រសួងពាណិជ្ជកម្ម។

## ២. មូលដ្ឋាននៃការរៀបចំ

ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលសម្រាប់ដំណាច់ការិយបរិច្ឆេទ៩ខែ ដែលបានបញ្ចប់នាថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ ត្រូវបានរៀបចំដោយអនុលោមតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជាលេខ ៣៤ ស្តីពីរបាយការណ៍ហិរញ្ញវត្ថុចន្លោះពេល ("CIAS ៣៤")។ ព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល មិនបានរួមបញ្ចូលកំណត់សម្គាល់ទាំងអស់ដូចនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចប្រចាំឆ្នាំនោះទេ។ ដូច្នេះ របាយការណ៍នេះ ត្រូវអានដោយភ្ជាប់ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ដែលត្រូវបានរៀបចំឡើងស្របតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("CIFRSs")។ គោលនយោបាយគណនេយ្យសំខាន់ៗ ដែលប្រើក្នុងការរៀបចំព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល គឺស្របតាមគោលនយោបាយគណនេយ្យសំខាន់ៗដែលបានប្រើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់។

## ៣. រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់បង្ហាញ

រូបិយវត្ថុជាតិនៃព្រះរាជាណាចក្រកម្ពុជា គឺខ្មែររៀល ("KHR")។ ប៉ុន្តែដោយសារក្រុមហ៊ុនមានប្រតិបត្តិការអាជីវកម្ម និងការរក្សាកំណត់ត្រាគណនេយ្យចម្បងជាប្រាក់ដុល្លារអាមេរិក ក្រុមប្រឹក្សាភិបាល បានកំណត់យករូបិយប័ណ្ណដុល្លារអាមេរិក ជារូបិយប័ណ្ណគោលរបស់ក្រុមហ៊ុនសម្រាប់គោលបំណងក្នុងការវាស់វែង និងបង្ហាញ ព្រោះវាបានឆ្លុះបញ្ចាំងពីខ្លឹមសារសេដ្ឋកិច្ចនៃព្រឹត្តិការណ៍ និងកាលៈទេសៈរបស់ក្រុមហ៊ុន។

ប្រតិបត្តិការជារូបិយប័ណ្ណបរទេសក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក ដោយប្រើប្រាស់អត្រាប្តូរប្រាក់ទូទៅនៅកាលបរិច្ឆេទនៃប្រតិបត្តិការ។ ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុល ដែលកំណត់ជារូបិយប័ណ្ណក្រៅពីប្រាក់ដុល្លារអាមេរិក នៅកាលបរិច្ឆេទនៃរបាយការណ៍ ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិកដោយប្រើប្រាស់អត្រាប្តូរប្រាក់ទូទៅនៅកាលបរិច្ឆេទនោះ។ លម្អៀងពីការប្តូររូបិយប័ណ្ណ ដែលបានកើតឡើងពីការប្តូរប្រាក់ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលលម្អិតផ្សេងៗ។

ការប្តូររូបិយប័ណ្ណពីប្រាក់ដុល្លារអាមេរិកទៅជាខ្មែររៀលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ គឺក្នុងគោលបំណងដើម្បីអនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្មនៃកម្ពុជា (ខែមេសា ឆ្នាំ២០១៦) ព្រមទាំងត្រូវបានធ្វើឡើង ដោយប្រើប្រាស់អត្រាប្តូរប្រាក់ជាផ្លូវការដែលបានបង្ហាញជាប្រាក់រៀលដោយយោងទៅតាមអត្រាប្តូរប្រាក់ក្នុង ១ដុល្លារអាមេរិកដូចដែលបានប្រកាសដោយធនាគារជាតិនៃកម្ពុជា ដូចខាងក្រោម៖

| | ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ | ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ |
|---|---|---|---|
| អត្រាប្តូរប្រាក់ចុងគ្រា | **៤.១១៩** | ៤.០៧៩ | ៤.០៧៤ |
| អត្រាប្តូរប្រាក់មធ្យម (៦ខែ)* | **៤.០៧៤** | ៤.០៦៦ | ៤.០៦៨ |
| អត្រាប្តូរប្រាក់មធ្យម (៣ខែ) * | **៤.១០១** | ៤.០៧៦ | |

**អត្រាប្តូរប្រាក់មធ្យមត្រូវបានគណនាដោយប្រើប្រាស់អត្រាប្តូរប្រាក់ប្រចាំថ្ងៃក្នុងការិយបរិច្ឆេទ*

អត្រាប្តូរប្រាក់ទាំងនេះ មិនត្រូវបានធ្វើសវនកម្ម និងមិនត្រូវបានបកស្រាយថាជាតំណាងនៃប្រាក់ដុល្លាអាមេរិក ឬដែលត្រូវបាន ឬអាចនឹងត្រូវបានប្តូរទៅជាប្រាក់រៀលនៅថ្ងៃអនាគតតាមអត្រាដែលបានបង្ហាញនេះ ឬអត្រាប្តូរប្រាក់ផ្សេងទៀតឡើយ។

### សមតុល្យនៃរូបិយប័ណ្ណបរទេស

ខ្ទង់មិនមែនជារូបិយវត្ថុ គឺមិនត្រូវបានប្តូរឡើងវិញនៅចុងការិយបរិច្ឆេទទេ ហើយត្រូវបានវាស់វែងតាមថ្លៃដើមប្រវត្តិសាស្ត្រ (បានប្តូររូបិយប័ណ្ណដោយប្រើប្រាស់អត្រាប្តូរប្រាក់នៅកាលបរិច្ឆេទនៃប្រតិបត្តិការ) លើកលែងខ្ទង់មិនមែនរូបិយវត្ថុដែលត្រូវបានវាស់វែងតាមតម្លៃសមស្រប ត្រូវបានប្តូរដោយប្រើប្រាស់អត្រាប្តូរប្រាក់នៅកាលបរិច្ឆេទដែលតម្លៃសមស្របត្រូវបានកំណត់។

## ៤. គោលនយោបាយគណនេយ្យសំខាន់ៗ

គោលនយោបាយគណនេយ្យ និងវិធីសាស្ត្រគណនាដែលបានអនុម័ត គឺស្របទៅជាមួយនឹងវិធីសាស្ត្រដែលបានអនុម័តក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែលបានធ្វើសវនកម្មរួចគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់។

### ៤.១. ប្រតិបត្តិការតាមផ្នែក

ប្រតិបត្តិការតាមផ្នែក ជាសមាសធាតុរបស់ក្រុមហ៊ុនដែលពាក់ព័ន្ធក្នុងសកម្មភាពអាជីវកម្ម ហើយអាចទទួលបានប្រាក់ចំណូល និងបង្កើតចំណាយ រួមទាំងចំណូល និងចំណាយដែលទាក់ទងជាមួយប្រតិបត្តិការនូវរាល់សមាសធាតុណាមួយរបស់ក្រុមហ៊ុន។ លទ្ធផលប្រតិបត្តិការតាមផ្នែកទាំងអស់ ត្រូវបានត្រួតពិនិត្យយ៉ាងទៀតទាត់ដោយប្រធានប្រតិបត្តិការជាអ្នកធ្វើសេចក្តីសម្រេចចិត្ត ដើម្បីធ្វើការសម្រេចអំពីធនធានដែលត្រូវបែងចែកទៅតាមផ្នែក និងវាយតម្លៃទៅលើលទ្ធផលរបស់វា ព្រមទាំងសម្រាប់ព័ត៌មានហិរញ្ញវត្ថុដាច់ដោយឡែកដែលកើតមាន។

ក្រុមហ៊ុនមានផ្នែកមួយដែលអាចរាយការណ៍បាន គឺការសាងសង់អចលនទ្រព្យ។ ប្រធានប្រតិបត្តិការ ជាអ្នកធ្វើសេចក្តីសម្រេច និងធ្វើការត្រួតពិនិត្យលើរបាយការណ៍គ្រប់គ្រងផ្ទៃក្នុង ដែលរាយការណ៍ពីលទ្ធផលតាមផ្នែកទាំងមូលរបស់ក្រុមហ៊ុន ដើម្បីធ្វើការវាយតម្លៃលើលទ្ធផលតាមផ្នែកដែលអាចរាយការណ៍បាន។

### ៤.២. រដូវកាល

សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុន គឺការសាងសង់អចលនទ្រព្យ។ មិនមានការប្រែប្រួលកត្តាពាក់ព័ន្ធសំខាន់ៗនៃសកម្មភាពអាជីវកម្មនេះឡើយ។

## ៥. ការប៉ាន់ស្មានរបស់គណៈគ្រប់គ្រង

នៅពេលរៀបចំព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ គណៈគ្រប់គ្រងធ្វើការវិនិច្ឆ័យ ការប៉ាន់ស្មាន និងការសន្មតជាច្រើនអំពីការទទួលស្គាល់ និងវាស់វែងទ្រព្យសកម្ម បំណុល ចំណូល និងចំណាយ។ លទ្ធផលជាក់ស្តែងអាចខុសពីលទ្ធផលនៃការវិនិច្ឆ័យ ប៉ាន់ស្មាន និងសន្មតដែលបានធ្វើឡើងដោយគណៈគ្រប់គ្រង និងកម្រស្មើនឹងលទ្ធផលដែលបានប៉ាន់ស្មាន។

ការវិនិច្ឆ័យ ការប៉ាន់ស្មាន និងការសន្មត ដែលបានអនុវត្តនៅក្នុងព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល រួមទាំងប្រភពសំខាន់ៗនៃភាពមិនប្រាកដប្រជានៃការប៉ាន់ស្មាន គឺដូចគ្នានឹងអ្វីដែលបានអនុវត្តនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ក្រុមហ៊ុនគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់។

(ទំព័រនេះត្រូវទុកឱ្យចន្លោះទទេដោយចេតនា)

## ៦. ទ្រព្យសម្បត្តិ និងបរិក្ខារ

បម្រែបម្រួលសមតុល្យយោងរបស់ទ្រព្យសម្បត្តិ និងបរិក្ខាររបស់ក្រុមហ៊ុនមានដូចខាងក្រោម៖

| | ដី<br>ដុល្លារអាមេរិក | អគារ<br>ដុល្លារអាមេរិក | គ្រឿងសង្ហារឹម និង<br>គ្រឿងបំពាក់<br>ដុល្លារអាមេរិក | បរិក្ខារ<br>ការិយាល័យ<br>ដុល្លារអាមេរិក | បរិក្ខារកុំព្យូទ័រ<br>ដុល្លារអាមេរិក | ការកែលម្អទ្រព្យជួល<br>ដុល្លារអាមេរិក | ដុល្លារអាមេរិក | សរុប<br>ពាន់រៀល<br>(កំណត់សម្គាល់ ៣) |
|---|---|---|---|---|---|---|---|---|
| (បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម) | | | | | | | | |
| **សមតុល្យយោងដុល** | | | | | | | | |
| សមតុល្យគិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០២២ | ៥៦០.០០០ | ៩៦.៥០០ | ១៥.៣២០ | - | ៤.៣៧៤ | ១៦.៥០៤ | ៦៩២.៦៩៨ | ២.៨២២.០៥២ |
| ការធ្វើចំណាត់ថ្នាក់ឡើងវិញ | - | - | - | ១.៥៥១ | (១.៥៥១) | - | - | - |
| ទិញបន្ថែម | - | ១.១៤៦ | ១.៤០០ | ១.២៦៥ | ១.៣២០ | - | ៥.១៣១ | ២០.៩០៤ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | ៣១.៤០២ |
| **សមតុល្យគិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២** | **៥៦០.០០០** | **៩៧.៦៤៦** | **១៦.៧២០** | **២.៨១៦** | **៤.១៤៣** | **១៦.៥០៤** | **៦៩៧.៨២៩** | **២.៨៧៤.៣៥៨** |
| **រំលស់បង្គរ** | | | | | | | | |
| សមតុល្យគិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០២២ | - | (១៧.៥៧០) | (៥.៦២០) | - | (២.៣៩៧) | (១.៦៥០) | (២៧.២៣៧) | (១១០.៩៦៤) |
| ការធ្វើចំណាត់ថ្នាក់ឡើងវិញ | - | - | - | (៤៧៧) | ៤៧៧ | - | - | - |
| រំលស់ | - | (៧.២៩៥) | (២.៦៨៩) | (៤៥៧) | (៣៩៥) | (១.២៣៨) | (១២.០៧៤) | (៤៩.១៨៩) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | | - | - | (១.៧៦៩) |
| **សមតុល្យគិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២** | - | (២៤.៨៦៥) | (៨.៣០៩) | (៩៣៤) | (២.៣១៥) | (២.៨៨៨) | (៣៩.៣១១) | (១៦១.៩២២) |
| **សមតុល្យយោងគិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២** | ៥៦០.០០០ | ៧២.៧៨១ | ៨.៤១១ | ១.៨៨២ | ១.៨២៨ | ១៣.៦១៦ | ៦៥៨.៥១៨ | ២.៧១២.៤៣៦ |

គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ គណៈគ្រប់គ្រងជឿជាក់ថាសមតុល្យដែលអាចប្រមូលមកវិញបានរបស់ទ្រព្យសម្បត្តិ និងបរិក្ខាររបស់ក្រុមហ៊ុនលើសពីតម្លៃយោងរបស់វា ដូចនេះហើយមិនមានឱនភាពលើការខាតបង់តម្លៃត្រូវបានទទួលស្គាល់ឡើយ។

## ៦. ទ្រព្យសម្បត្តិ និងបរិក្ខារ (ត)

| | ដី | អគារ | គ្រឿងសង្ហារឹម និង គ្រឿងបំពាក់ | បរិក្ខារកុំព្យូទ័រ | ការកែលម្អទ្រព្យជួល | | សរុប |
|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) |
| (បានធ្វើសវនកម្មរួច) | | | | | | | |
| សមតុល្យយោងដុល | | | | | | | |
| សមតុល្យគិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ | ៥៦០.០០០ | ៩៦.៥០០ | ៣.១០២ | ២.២៦១ | - | ៦៦១.៨៦៣ | ២.៦៧៧.២៣៦ |
| ទិញបន្ថែម | - | - | ១២.៥១៣ | ២.៥១២ | ១៦.៥០៤ | ៣១.៥២៩ | ១២៨.២៦០ |
| លុបចោល | - | - | (២៩៥) | (៣៩៩) | - | (៦៩៤) | (២.៨២៣) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | ១៩.៣៧៩ |
| សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | ៥៦០.០០០ | ៩៦.៥០០ | ១៥.៣២០ | ៤.៣៧៤ | ១៦.៥០៤ | ៦៩២.៦៩៨ | ២.៨២២.០៥២ |
| រំលស់បង្គរ | | | | | | | |
| សមតុល្យគិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ | - | (៧.៩២០) | (២.៥៦៤) | (១.៩៩៣) | - | (១២.៤៧៧) | (៥០.៤៧០) |
| រំលស់ | - | (៩.៦៥០) | (៣.៣៥១) | (៨០៣) | (១.៦៥០) | (១៥.៤៥៤) | (៦២.៨៦៧) |
| លុបចោល | - | - | ២៩៥ | ៣៩៩ | - | ៦៩៤ | ២.៨២៣ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | (៤៥០) |
| សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | - | (១៧.៥៧០) | (៥.៦២០) | (២.៣៩៧) | (១.៦៥០) | (២៧.២៣៧) | (១១០.៩៦៤) |
| សមតុល្យយោងគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | ៥៦០.០០០ | ៧៨.៩៣០ | ៩.៧០០ | ១.៩៧៧ | ១៤.៨៥៤ | ៦៦៥.៤៦១ | ២.៧១១.០៨៨ |

នៅថ្ងៃទី១ ខែសីហា ឆ្នាំ២០១៦ ក្រុមហ៊ុនបានធ្វើកិច្ចសន្យា និងសេចក្តីប្រកាសលើបរធនបាលកិច្ចជាមួយម្ចាស់ភាគហ៊ុនរបស់ខ្លួនក្នុងការកាន់កាប់ដីដែលបានប្រើសម្រាប់ការិយាល័យតាំងបង្ហាញរបស់ខ្លួន។

## ៧. សន្និធិអចលនទ្រព្យ

ព័ត៌មានលម្អិតពីសន្និធិអចលទ្រព្យរបស់ក្រុមហ៊ុនមានដូចខាងក្រោម៖

| | **(បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម)** | | (បានធ្វើសវនកម្មរួច) | |
|---|---|---|---|---|
| | **ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២** | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | ដុល្លារអាមេរិក | ពាន់រៀល |
| | | **(កំណត់សម្គាល់ ៣)** | | (កំណត់សម្គាល់ ៣) |
| បន្ទប់ខុនដូរសម្រាប់លក់ | **៧៦.២៤៦** | **៣១៤.០៥៧** | ៧៦.២៤៦ | ៣១០.៦២៦ |

មិនមានសន្និធិបានលក់ចេញក្នុងអំឡុងការិយបរិច្ឆេទទេ (ឆ្នាំ២០២១៖ មានសមតុល្យ ៦៥០.១៦៨ ដុល្លារអាមេរិក ឬស្មើនឹង ២.៦៤៣.៥៨៣.០០០រៀល)។

គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ សន្និធិដែលមានថ្លៃដើមក្នុងសមតុល្យ ៣៨.១២៣ ដុល្លារអាមេរិក ឬស្មើនឹង ១៥៧.០២៩.០០០ រៀល (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១៖ មានសមតុល្យ ៣៨.១២៣ ដុល្លារអាមេរិក ឬស្មើនឹង ១៥៥.៣១៣.០០០ រៀល) ត្រូវបានដាក់ធានាជាទ្រព្យបញ្ចាំលើប្រាក់កម្ចីរបស់ក្រុមហ៊ុនដូចដែលបានបញ្ជាក់នៅក្នុងកំណត់សម្គាល់ ១៧ (ក)។

គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ គណៈគ្រប់គ្រងជឿជាក់ថាថ្លៃដើមសន្និធិរបស់ក្រុមហ៊ុនលើសពីតម្លៃលក់សុទ្ធរបស់វា ដូច្នេះហើយមិនមានសំវិធានធន ត្រូវបានទទួលស្គាល់នោះឡើយ។

## ៨. ថ្លៃដើមអភិវឌ្ឍទ្រព្យសម្បត្តិ

បម្រែបម្រួលសមតុល្យយោងនៃថ្លៃដើមអភិវឌ្ឍទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនមានដូចខាងក្រោម៖

| | **(បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម)** | | (បានធ្វើសវនកម្មរួច) | |
|---|---|---|---|---|
| | **ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២** | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | ដុល្លារអាមេរិក | ពាន់រៀល |
| | | **(កំណត់សម្គាល់ ៣)** | | (កំណត់សម្គាល់ ៣) |
| **ថ្លៃដើម** | | | | |
| សមតុល្យដើមការិយបរិច្ឆេទ/ឆ្នាំ | **៥.៤៤៨.០៧៥** | **២២.១៩៥.៤៥៨** | ១.៨៩៩.៦៣២ | ៧.៦៨៤.០១១ |
| ដីសម្រាប់អភិវឌ្ឍអចលនទ្រព្យ ឬទ្រព្យសម្បត្តិ | **២០០.០០០** | **៨១៤.៨០០** | - | - |
| ថ្លៃដើមអភិវឌ្ឍបានធ្វើមូលធនកម្មក្នុងការិយបរិច្ឆេទ/ឆ្នាំ | **៣.៦៤៥.៣០៧** | **១៤.៨៥០.៩៨១** | ៣.៥៤៨.៤៤៣ | ១៤.៤៣៥.០៦៦ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | **-** | **៤១៨.២០១** | - | ៧៦.៣៨១ |
| **សមតុល្យនាចុងការិយបរិច្ឆេទ/ឆ្នាំ** | **៩.២៩៣.៣៨២** | **៣៨.២៧៩.៤៤០** | ៥.៤៤៨.០៧៥ | ២២.១៩៥.៤៥៨ |

## ៩. ថ្លៃដើមកិច្ចសន្យា

| | (បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម) ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ | | (បានធ្វើសវនកម្មរួច) ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់ ៣)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) |
| សមតុល្យដើមការិយបរិច្ឆេទ/ឆ្នាំ | **១០៥.៤៣៦** | **៤២៩.៥៤៦** | ៣០.៤៦៤ | ១២៣.២២៧ |
| បន្ថែម | **៣០.៤០៧** | **១២៣.៨៧៨** | ៧៤.៩៧២ | ៣០៤.៩៨៦ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | **៦.១១៣** | - | ១.៣៣៣ |
| **សមតុល្យនាចុងការិយបរិច្ឆេទ/ឆ្នាំ** | **១៣៥.៨៤៣** | **៥៥៩.៥៣៧** | ១០៥.៤៣៦ | ៤២៩.៥៤៦ |

ចំណាយក្នុងការធ្វើកិច្ចសន្យាតំណាងឱ្យសេវាកម្រៃជើងសា ដែលបានទូទាត់ទៅឱ្យអន្តរការីក្នុងការធ្វើកិច្ចសន្យាលក់លំនៅដ្ឋាន។

មិនមានការខាតបង់លើឱនភាពនៃតម្លៃពាក់ព័ន្ធទៅនឹងថ្លៃដើមដែលបានធ្វើមូលធនកម្មនោះទេ។

## ១០. (បំណុល)/ទ្រព្យសកម្មកិច្ចសន្យា

ព័ត៌មានលម្អិតនៃ(បំណុល)/ទ្រព្យសកម្មកិច្ចសន្យា របស់ក្រុមហ៊ុនមានដូចខាងក្រោម៖

| | (បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម) ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ | | (បានធ្វើសវនកម្មរួច) ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់ ៣)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) |
| **ថ្លៃដើម** | | | | |
| សមតុល្យដើមការិយបរិច្ឆេទ/ឆ្នាំ | **១.៣៩៤.១៣៥** | **៥.៦៧៩.៧០៦** | ១.៥៧៩.៦៩៦ | ៦.៣៨៩.៨៧០ |
| ចំណូលបានទទួលស្គាល់ក្នុងអំឡុងការិយបរិច្ឆេទបានពី៖ | | | | |
| ការលក់អចលទ្រព្យ | - | - | ១.៣៤២.៦៤៩ | ៥.៤៦១.៨៩៦ |
| បុព្វលាភពីការពន្យារការទូទាត់ | - | - | (៧២.៧៩៨) | (២៩៦.១៤២) |
| វិក្កយបត្រក្នុងការទូទាត់ | **(១.៦៥៩.៥៦៧)** | **(៦.៧៦១.០៧៦)** | (១.៤៥៥.៤១២) | (៥.៩២០.៦១៦) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | **(១១.៩៤៤)** | - | ៤៤.៦៩៨ |
| **សមតុល្យនាចុងការិយបរិច្ឆេទ/ឆ្នាំ** | **(២៦៥.៤៣២)** | **(១.០៩៣.៣១៤)** | ១.៣៩៤.១៣៥ | ៥.៦៧៩.៧០៦ |

មិនមានចំណូលដែលត្រូវបានទទួលស្គាល់ក្នុងការិយបរិច្ឆេទពាក់ព័ន្ធទៅនឹងបំណុលកិច្ចសន្យាដែលបានទទួលស្គាល់ពីការិយបរិច្ឆេទចាស់ឡើយ (ឆ្នាំ២០២១៖គ្មាន)។

គណនីត្រូវទទួលដែលទាក់ទងទៅនឹងសមតុល្យអតិថិជនជំពាក់ គឺផ្អែកលើតារាងទូទាត់សងដែលមានចែងក្នុងកិច្ចព្រមព្រៀងទិញលក់។ គិតត្រឹមចុងការិយបរិច្ឆេទនៃរបាយការណ៍ សមតុល្យរបស់គណនីត្រូវទទួល មានសមតុល្យ ៦៥.៨៥០ ដុល្លារអាមេរិក ឬ ២៧១.២៣៦.០០០ រៀល (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១៖ មានសមតុល្យ ១៩.៣៩០ ដុល្លារអាមេរិក ឬ៧៨.៩៩៥.០០០ រៀល)។

តារាងខាងក្រោមបង្ហាញពីសមតុល្យយោងរបស់(បំណុល)/ទ្រព្យសកម្មកិច្ចសន្យា របស់ក្រុមហ៊ុន៖

| | **(បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម)** | | (បានធ្វើសវនកម្មរួច) | |
|---|---|---|---|---|
| | **ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២** | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | ដុល្លារអាមេរិក | ពាន់រៀល |
| | | **(កំណត់សម្គាល់ ៣)** | | (កំណត់សម្គាល់ ៣) |
| ទ្រព្យសកម្មកិច្ចសន្យា | **២.៧៦៧.៤៥៤** | **១១.៣៩៩.១៤៣** | ២.៩៩៣.០៦៦ | ១២.១៩៣.៧៥១ |
| បំណុលកិច្ចសន្យា | **(៣.០៣២.៨៨៦)** | **(១២.៤៩២.៤៥៧)** | (១.៥៩៨.៩៣១) | (៦.៥១៤.០៤៥) |
| | **(២៦៥.៤៣២)** | **(១.០៩៣.៣១៤)** | ១.៣៩៤.១៣៥ | ៥.៦៧៩.៧០៦ |

មិនមានការខាតបង់លើឱនភាពត្រូវបានទទួលស្គាល់លើទ្រព្យសកម្មកិច្ចសន្យា និងគណនីត្រូវទទួលក្នុងការិយបរិច្ឆេទនៃរបាយការណ៍ឡើយ។

## ១១. ចំណាយបង់មុន និងគណនីត្រូវទទួលផ្សេងៗ

ព័ត៌មានលម្អិតលើចំណាយបង់មុន និងគណនីត្រូវទទួលផ្សេងៗរបស់ក្រុមហ៊ុនមានដូចខាងក្រោម៖

| | **(បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម)** | | (បានធ្វើសវនកម្មរួច) | |
|---|---|---|---|---|
| | **ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២** | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | ដុល្លារអាមេរិក | ពាន់រៀល |
| | | **(កំណត់សម្គាល់ ៣)** | | (កំណត់សម្គាល់ ៣) |
| សំណងលើការខូចខាតដែលត្រូវទទួល | **៣០៥.០០០** | **១.២៥៦.២៩៥** | ៣០៥.០០០ | ១.២៤២.៥៧០ |
| ប្រាក់បញ្ញើ | **១.៦៤០** | **៦.៧៥៥** | - | - |
| ការទូទាត់ជាមុន | **២៧.៥០០** | **១១៣.២៧៣** | ២៧.៥០០ | ១១២.០៣៥ |
| គណនីត្រូវទទួលពីភាគីពាក់ព័ន្ធ | **៣.១៦៦** | **១៣.០៤០** | ១២.០១១ | ៤៨.៩៣៣ |
| ចំណាយបង់មុន | - | - | ២២០.០៨៣ | ៨៩៦.៦១៨ |
| | **៣៣៧.៣០៦** | **១.៣៨៩.៣៦៣** | ៥៦៤.៥៩៤ | ២.៣០០.១៥៦ |

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២១ គណនីចំណាយបង់មុនតំណាងឱ្យថ្លៃដើម IPO ដែលបានធ្វើមូលធនកម្ម។

## ១២. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងការិយបរិច្ឆេទនៃរបាយការណ៍ដូចដែលបានបង្ហាញនៅក្នុងរបាយការណ៍លំហូរសាច់ប្រាក់ដែលអាចធ្វើការផ្ទៀងផ្ទាត់បានជាមួយធាតុគណនីដែលពាក់ព័ន្ធនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុមានដូចខាងក្រោម៖

| | **(បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម)** | | (បានធ្វើសវនកម្មរួច) | |
|---|---|---|---|---|
| | **ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២** | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | ដុល្លារអាមេរិក | ពាន់រៀល |
| | | **(កំណត់សម្គាល់ ៣)** | | (កំណត់សម្គាល់ ៣) |
| សាច់ប្រាក់ក្នុងធនាគារ | **៤៧.៥៦២** | **១៩៥.៩០៨** | ៨៩.៨០៣ | ៣៦៥.៨៥៧ |
| ប្រាក់បញ្ញើមានកាលកំណត់ | **១១២.០២០** | **៤៦១.៤១០** | ១១០.៨៣១ | ៤៥១.៥២៥ |
| សាច់ប្រាក់ក្នុងដៃ | **៦១.៨៥៦** | **២៥៤.៧៨៥** | ៦.៩៦៧ | ២៨.៣៨៤ |
| | **២២១.៤៣៨** | **៩១២.១០៣** | ២០៧.៦០១ | ៨៤៥.៧៦៦ |

ប្រាក់បញ្ញើមានកាលកំណត់ទាក់ទងនឹងប្រាក់បញ្ញើរយៈពេលវែងនៅក្នុងធនាគារដែលមានកេរ្តិ៍ឈ្មោះនៅក្នុងប្រទេស ដែលក្រុមហ៊ុនបានតម្កល់នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២១ ហើយមានកាលកំណត់រយៈពេលបីឆ្នាំ និងទទួលបានការប្រាក់ថេរចំនួន ១,៥%។ ក្រោមលក្ខខណ្ឌកិច្ចសន្យាប្រាក់បញ្ញើមានកាលកំណត់ ក្រុមហ៊ុនមានឆន្ទានុសិទ្ធិក្នុងការដកប្រាក់បញ្ញើនេះបានគ្រប់ពេល។ ដូច្នេះវាត្រូវបានកត់ត្រាជាសាច់ប្រាក់សមមូល។

សាច់ប្រាក់ក្នុងធនាគារទទួលបានការប្រាក់តាមអត្រាការប្រាក់លើប្រាក់បញ្ញើរបស់ធនាគារក្នុងអត្រា 0,១១% (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១៖ 0,១១%)។

ចំណូលការប្រាក់ដែលបានទទួលពីសាច់ប្រាក់ក្នុងធនាគារ និងប្រាក់បញ្ញើមានកាលកំណត់មានសមតុល្យ ១.៤០៥ ដុល្លារអាមេរិក ឬ ៥.៧២៤.000 រៀល ក្នុងអំឡុងការិយបរិច្ឆេទ (ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១៖ មានសមតុល្យ ៥៥២ ដុល្លារអាមេរិក ឬ ២.២២៤.000 រៀល)។

## ១៣. សិទ្ធិប្រើប្រាស់លើទ្រព្យសកម្ម និងបំណុលភតិសន្យា

ក្រុមហ៊ុនមានកិច្ចសន្យាភតិសន្យាសម្រាប់អគារដែលប្រើប្រាស់សម្រាប់ជាអគារការិយាល័យរបស់ខ្លួនដែលមានរយៈ ២ ឆ្នាំ ដែលមិនអាចលុបចោលបាន ដោយមិនមានជម្រើសក្នុងការបន្តបន្ទាប់ពីមានការបញ្ចប់នៃរយៈពេលជួល។ ការរឹតត្បិតពីការជួល និងការជួលបន្តទ្រព្យសកម្មភតិសន្យា មិនមានចំពោះក្រុមហ៊ុននោះទេ។

បម្រែបម្រួលលើសមតុល្យយោងនៃសិទ្ធិប្រើប្រាស់លើទ្រព្យសកម្មរបស់ក្រុមហ៊ុនមានដូចខាងក្រោម៖

| | **(បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម)** | | (បានធ្វើសវនកម្មរួច) | |
|---|---|---|---|---|
| | **ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២** | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
| | **ដុល្លារអាមេរិក** | **ពាន់រៀល (កំណត់សម្គាល់ ៣)** | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣) |
| **ថ្លៃដើម** | | | | |
| សមតុល្យដើមគ្រា/ដើមឆ្នាំ | **១៤៨.០០៦** | **៦០២.៩៧៧** | ២០៤.១៦៤ | ៨២៥.៨៤៣ |
| បន្ថែម | - | - | ១៤៨.០០៦ | ៦០២.០៨៨ |
| ភតិសន្យាដែលបានបញ្ចប់ | (២៤.៥៣៨) | (៩៩.៦៦៨) | (២០៤.១៦៤) | (៨៣០.៥៣៩) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | **៥.៥៥៦** | - | ៥.៥៨៥ |
| **សមតុល្យចុងគ្រា/ចុងឆ្នាំ** | **១២៣.៤៦៨** | **៥០៨.៨៦៥** | ១៤៨.០០៦ | ៦០២.៩៧៧ |
| **រំលស់បង្គរ** | | | | |
| សមតុល្យដើមគ្រា/ដើមឆ្នាំ | **(៥៤.០១៥)** | **(២២០.០៥៨)** | (១៨៧.១៥០) | (៧៥៧.០២១) |
| រំលស់ | **(៤៦.៣០១)** | **(១៨៨.៦៣០)** | (៧១.០២៩) | (២៨៨.៩៤៦) |
| ភតិសន្យាដែលបានបញ្ចប់ | **២៣.១៤៨** | **៩៤.៣០៥** | ២០៤.១៦៤ | ៨៣០.៥៣៩ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | **(៣.៤៧២)** | - | (៤.៦៣០) |
| **សមតុល្យចុងគ្រា/ចុងឆ្នាំ** | **(៧៧.១៦៨)** | **(៣១៧.៨៥៥)** | (៥៤.០១៥) | (២២០.០៥៨) |
| **សមតុល្យយោងចុងគ្រា/ចុងឆ្នាំ** | **៤៦.៣០០** | **១៩០.៧១០** | ៩៣.៩៩១ | ៣៨២.៩១៩ |

នៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២១ ក្រុមហ៊ុនបានធ្វើកិច្ចសន្យាភតិសន្យាជាមួយម្ចាស់ភាគហ៊ុនមួយរូបដើម្បីជួលអគារសម្រាប់ធ្វើការិយាល័យអាជីវកម្មដែលកិច្ចសន្យានោះមានសុពលភាពរយៈពេល ២ឆ្នាំ។

បំណុលភតិសន្យា ជាផ្នែកនៃតម្លៃបច្ចុប្បន្នលើការទូទាត់ភតិសន្យាក្នុងរយៈពេលព្រមព្រៀងនៃភតិសន្យានោះ។

បម្រែបម្រួលបំណុលភតិសន្យាមានដូចខាងក្រោម៖

| | **(បានត្រួតពិនិត្យ តែមិនបានធ្វើសវនកម្ម)** | | (បានធ្វើសវនកម្មរួច) | |
|---|---|---|---|---|
| | **ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២** | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | |
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | ដុល្លារអាមេរិក | ពាន់រៀល |
